# ឃ្លាំមើលសភា និង តំណាងរាស្ត្រសំរាប់ខែធ្នូ ឆ្នាំ២០០៧

រដ្ឋសភាក្នុងខែធ្នូនេះ ហាក់មានភាពសកម្មជាងខែមុនៗ ដោយបានបើកសម័យប្រជុំរបស់ខ្លួនចំនួន **១៣ព្រឹក** ហើយបានពិភាក្សា និងអនុម័តរបៀបវារៈចំនួន ៨ ដែលក្នុងនោះរួមមាន**សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងកិច្ចព្រមព្រៀង**។ **ខុមហ្វ្រែល** សង្កេតឃើញថា អ្នកតំណាងរាស្ត្រ**ភាគច្រើនមកពីគណបក្សទាំងបី បានសាទរចំពោះសេចក្តីព្រាងច្បាប់នានាដែលបានអនុម័តក្នុងខែនេះ** ប៉ុន្តែអ្នកតំណាងរាស្ត្រមួយចំនួនក៏បាន**បង្ហាញពីកង្វល់ជុំវិញការអនុវត្តច្បាប់** ក៏ដូចជាផ្តល់អនុសាសន៍នូវផ្សេងៗទៀតផងដែរ។ ក្នុងសម័យប្រជុំសភាពេញអង្គនេះ អ្នកតំណាងរាស្ត្រមួយចំនួនបានបន្តលើកឡើងពីបញ្ហាក្នុងមណ្ឌលមួយចំនួន បើទោះបីជាវាមិនត្រូវនឹងប្រធានបទពិភាក្សាក៏ដោយ។

ក្នុងខែនេះដែរ ខុមហ្វ្រែលទទួលបានព័ត៌មានថា មាន**អ្នកតំណាងរាស្ត្រយ៉ាងតិចចំនួន ៣រូប បានដាក់លិខិតយ៉ាងតិចចំនួន ៥** ទៅកាន់ស្ថាប័នរាជរដ្ឋាភិបាល ដោយរួមទាំងការ**អញ្ជើញមន្ត្រីរាជរដ្ឋាភិបាលមកបំភ្លឺក្នុងនៅសម័យប្រជុំសភាពេញអង្គ**ផងដែរ ហើយអ្នកតំណាងរាស្ត្រមួយចំនួនមកពីគណបក្ស សមរង្ស៊ី បានស្នើធ្វើវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ។

ចំណែកការចុះទៅកាន់មូលដ្ឋានដោយអ្នកតំណាងរាស្ត្រវិញ តាមព័ត៌មាន ខុមហ្វ្រែលទទួលបានគឺមានការធ្លាក់ចុះបើប្រៀបធៀបទៅនឹងខែមុន ព្រោះអ្នកតំណាងរាស្ត្ររវល់ជាប់ប្រជុំនៅវិមានរដ្ឋសភា។

## ការចុះទៅកាន់មណ្ឌលនានារបស់អ្នកតំណាងរាស្ត្រ

ក្រាហ្វិចទី១: ភាគរយអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន នៃគណបក្សនីមួយៗធៀបនឹងគណបក្សរបស់ខ្លួន




នៅក្នុងខែធ្នូនេះ តាមព័ត៌មានដែលខុមហ្វ្រែលបានទទួល មានអ្នកតំណាងរាស្ត្រយ៉ាងតិចចំនួន **៣២រូប** ប៉ុណ្ណោះដែលបាន ចុះមូលដ្ឋានចំនួន ១០០ **លើក**។ ចំនួននេះមានការធ្លាក់ចុះបើធៀប ទៅនឹងខែមុនដែលមានអ្នកតំណាងរាស្ត្រយ៉ាងតិច **៣៥រូប** បានចុះមូលដ្ឋានយ៉ាងតិច **១២៥ លើក**។ គោលបំណងរបស់អ្នកតំណាងរាស្ត្រ ចុះទៅកាន់មូលដ្ឋាន មានដូចជា **ចូលរួមក្នុងវេទិកា ចុះអមដំណើរថ្នាក់ដឹកនាំ ចុះពង្រឹងបណ្តាញគណបក្ស** និងពិសេស **ចុះសួរសុខទុក្ខ និងចែកអំណោយ**។ ដោយឡែកខុមហ្វ្រែលមិនបានទទួលព័ត៌មានការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រដើម្បី**ធ្វើការអន្តរាគមន៍ និងដោះស្រាយបញ្ហា**នានាជូនប្រជាពលរដ្ឋនោះទេ។ ចំណែកមណ្ឌលដែលខុមហ្វ្រែល មិនបានទទួលព័ត៌មាន ឬមិនមានព័ត៌មានអំពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្ររួមមាន **មណ្ឌលស្ទឹងត្រែង និងប៉ៃលិន**។ ក្នុងចំណោមតំណាងរាស្ត្រទាំង **៣២រូប** ដែលចុះមូលដ្ឋាន មានអ្នកតំណាងរាស្ត្រមកពីគណបក្ស**ប្រជាជនកម្ពុជា**ចំនួន **២១រូប** (ស្មើនឹង ២៩%នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ដែលមានចំនួន ៧៣រូប) បានចុះទៅកាន់មូលដ្ឋានយ៉ាងតិចចំនួន **៥២លើក** ស្មើនឹង **៥២%** នៃការចុះមូលដ្ឋាន របស់អ្នកតំណាងរាស្ត្រសរុប។ ចំណែកតំណាងរាស្ត្រ គណបក្ស **សមរង្ស៊ី** យ៉ាងតិចចំនួន **៧រូប** (ស្មើនឹង ២៩% នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ដែលមានចំនួន ២៤រូប) បានចុះមូលដ្ឋានយ៉ាងតិចចំនួន **៣១ លើក** ស្មើនឹង **៣១%**នៃការចុះមូលដ្ឋានសរុប ហើយអ្នកតំណាងរាស្ត្រគណបក្ស **ហ៊្វុនស៊ិនប៉ិច** យ៉ាងតិចចំនួន **៥ រូប** (ស្មើនឹង ១៩% នៃ អ្នកតំណាងរាស្ត្រ គណបក្សនេះទាំងអស់ដែលមានចំនួន ២៦រូប) បានចុះមូលដ្ឋានយ៉ាងតិចចំនួន **១៧លើក** ស្មើនឹង **១៧%** នៃការចុះមូលដ្ឋានសរុប។

# សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទិនសភា និង តំណាងរាស្ត្រ

## អគ្គលេខាធិការរដ្ឋសភា: អ្នកតំណាងរាស្ត្រនៅមានភាពក្មេងខ្ចីក្នុងការអនុវត្តតួនាទីរបស់ខ្លួន

អគ្គលេខាធិការរដ្ឋសភាឯកឧត្តម **ឡេង ប៉េងឡុង** បានថ្លែងថា: *"នៅក្នុងបណ្តាភារៈទាំង៣ របស់សមាជិករដ្ឋសភា....... មានភារកិច្ចពីរគឺ ការត្រួតពិនិត្យរាជរដ្ឋាភិបាល និងការអនុវត្តតួនាទីជាតំណាងឃើញថាពុំទាន់បានរៀបចំបានល្អប្រសើរនៅឡើយ ។"*

ឯកឧត្តម **ឡេង ប៉េងឡុង** បានថ្លែងបែបនេះនៅក្នុងវេទិកាប្រធានស្តីពី បទពិសោធន៍នៃការអនុវត្តរបស់គម្រោងគាំទ្រនីតិបញ្ញត្តិកម្ពុជា-កាណាដា។ ឯកឧត្តម **ឡេង ប៉េងឡុង** បានបញ្ជាក់បន្ថែមទៀតថា ចំពោះការងារទាំងពីរខាងលើនេះ អ្នកតំណាងរាស្ត្រនៅមានបទពិសោធន៍ក្មេងខ្ចី ព្រមទាំងខ្វះខាតមធ្យោបាយយ៉ាងច្រើន ហើយការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលទាំង២៤ខេត្ត/ក្រុង ដែលមានភារកិច្ចសម្រួលដល់ការងាររបស់អ្នកតំណាងរាស្ត្រ និងសម្រួលដល់ការប្តឹងតវ៉ារបស់ប្រជាពលរដ្ឋ គឺមានតែឈ្មោះប៉ុណ្ណោះ និងមិនអាចបំពេញភារកិច្ចរបស់ខ្លួនឱ្យបានសមរម្យឡើយ ។

**ខុមហ្វ្រែល**ក៏សង្កេតឃើញដែរថា ខណៈដែលការិយាល័យតំណាងរាស្ត្រនៅមណ្ឌលមួយចំនួនខ្វះសម្ភារៈដើម្បីធ្វើការ បុគ្គលិកការិយា-ល័យតំណាងរាស្ត្រក៏មិនបានគោរពពេលវេលាធ្វើការទេ ដូចជានៅ មណ្ឌលកំពង់ស្ពឺជាដើម ។

## អ្នកតំណាងរាស្ត្រស្នើឱ្យរាជរដ្ឋាភិបាលការពារបរិស្ថាន និងធម្មជាតិ ទោះបីវាមិនមែនជាតំបន់ការពារធម្មជាតិក៏ដោយ

នៅពេលដែលតំបន់ការពារធម្មជាតិទាំង២៣កន្លែងក្នុងប្រទេសមានច្បាប់ដើម្បីការពារ អ្នកតំណាងរាស្ត្រមួយចំនួនក៏បានស្នើដល់**ក្រសួងបរិស្ថានឱ្យជួយពិនិត្យមើលបរិស្ថាន**នៅតំបន់ផ្សេងៗទៀតផងដែរ ។

អ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន មណ្ឌលកំពង់ចាម** បានលើកឡើងពី**បញ្ហាជីកយករ៉ែមាស** ដោយមានការបាញ់ទឹកដែលជាហេតុនាំឱ្យមានដីហូរចូលបឹងព្រែក ហើយនាំឱ្យមានការប៉ះពាល់ដល់ប្រជាពលរដ្ឋ។ អ្នកតំណាងរាស្ត្រ គី **លំអង មណ្ឌលបាត់ដំបង**បានបន្ថែមទៀតថា មានក្រុមហ៊ុនរុករករ៉ែមាសខ្លះ មិនទាន់បានចាប់ផ្តើមផង ក៏ប៉ុន្តែបានបំផ្លាញបរិស្ថានរួចទៅហើយ ហើយមាន **រោងចក្រមួយចំនួននៅតែបង្ហូរជាតិពុលចូលទន្លេ**។ អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង **អ្នកអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ សន្តា** បានស្នើឱ្យក្រសួងបរិស្ថានជួយពិនិត្យមើល**រមណីយដ្ឋាននៅតាមមាត់ទឹក** ដូចជានៅកៀនស្វាយជាដើម ។

## អ្នកតំណាងរាស្ត្របារម្ភពីការចាក់ដី លុបបឹង និងកោះ

អ្នកតំណាងរាស្ត្រមួយចំនួនបានបង្ហាញពីក្តីបារម្ភរបស់ខ្លួនចំពោះការចាក់ដីលុបបឹងដែលអាចនាំឱ្យទីក្រុងលិចទឹក និងការចាក់ដីនៅលើកោះធ្វើឱ្យរាំងស្ទះដល់ចរន្តទឹក ។

អ្នកតំណាងរាស្ត្រ **ហូ វ៉ាន់ មណ្ឌលភ្នំពេញ** បានសួរដល់រដ្ឋមន្ត្រីក្រសួងបរិស្ថាន**ពីវិធានការដើម្បីការពារផលប៉ះពាល់ពីការលុបបឹងនានា** ហើយអ្នកតំណាងរាស្ត្រ **ម៉ោញ សាផាន មណ្ឌលកំពង់ចាម** បានស្នើឱ្យមានការយកដីដែលត្រូវបានគេយកទៅចាក់លុបនៅកោះពេជ្រជាច្រើនហិកតាចេញវិញ។ ទោះបីយ៉ាងណា នៅក្នុងសម័យប្រជុំនោះ ខុមហ្វ្រែលសង្កេតឃើញថាមិនមានការឆ្លើយតបពីតំណាងក្រសួងបរិស្ថាននោះទេ។

## ក្រុមអ្នកតំណាងរាស្ត្របក្សជំទាស់ស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ

ក្នុងខែធ្នូនេះ អ្នកតំណាងរាស្ត្រចំនួន **១២រូបមកពីគណបក្សសមរង្ស៊ី** ដែលតំណាងដោយឯកឧត្តម **សុន ឆ័យ** បានស្នើដល់ប្រធានរដ្ឋសភាធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា **១១៨ ថ្មី និងមាត្រា ១៩៩ ថ្មី**។

អ្នកតំណាងរាស្ត្រទាំង ១២រូប បានស្នើកែសម្រួលមាត្រា ១១៨ ថ្មីថា សមាសភាពគណៈរដ្ឋមន្ត្រីគឺរាប់ត្រឹមនាយករដ្ឋមន្ត្រី ឧបនាយក-ករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីប៉ុណ្ណោះ (មាត្រាចាស់មានរាប់បញ្ចូលទាំងរដ្ឋលេខាធិការ) ហើយរាល់ពេលមានការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មី ត្រូវមានគណៈរដ្ឋមន្ត្រីបណ្តោះអាសន្នមួយ ដែលបង្កើតឡើងក្នុងបំណងផ្តល់បរិយាកាសអព្យាក្រឹត សេរី និងយុត្តិធម៌ដល់ការបោះឆ្នោត។

ចំណែកមាត្រា ១៩៩ថ្មី ត្រូវបានស្នើកែសម្រួលដោយកំណត់តែមួយអាណត្តិរដ្ឋសភា សម្រាប់តំណែងជានាយករដ្ឋមន្ត្រី និងធានាដល់ការគោរពអំណាចគ្នារវាងគណបក្សសម្ព័ន្ធភាពក្នុងរាជរដ្ឋាភិបាល។

ទោះបីយ៉ាងណា មិនទាន់មានកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃរដ្ឋសភាដើម្បីសម្រេចថាយកសេចក្តីស្នើច្បាប់នេះមកពិភាក្សានៅឡើយទេ។

## អ្នកតំណាងរាស្ត្រមានមតិខ្វែងគ្នាពីការត្រួតពិនិត្យការងាររាជរដ្ឋាភិបាល

អ្នកតំណាងរាស្ត្រ **អាយ ខន មណ្ឌលកោះកុង** បានធ្វើការិះគន់អ្នកតំណាងរាស្ត្រ **សុន ឆៃ** មណ្ឌលភ្នំពេញចំពោះការស្នើសុំនានារបស់អ្នកតំណាងរាស្ត្រនេះថាមិនត្រឹមត្រូវតាមច្បាប់។

អ្នកតំណាងរាស្ត្រ **អាយ ខន** បានលើកឡើងក្នុងអំឡុងពេលពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាពថា កាលពីសភាពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៨ **ឯកឧត្តម សុន ឆ័យ** បានលើកសំណើឡើងដោយបំពាននឹងច្បាប់ថា សុំឱ្យមានការពិភាក្សារវាងគ្រប់គណៈកម្មការ និងក្រសួងទាំងអស់ដែលប្រើប្រាស់លុយរដ្ឋ។ នៅពេលសភាពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពី តំបន់ការពារធម្មជាតិ **ឯកឧត្តម សុន ឆ័យ** បានលើកសំណើមួយទៀត សុំឱ្យក្រសួងបរិស្ថានធ្វើសេចក្តីរាយការណ៍ និងចេញរបាយការណ៍មកដល់សភា តែត្រូវអ្នកតំណាងរាស្ត្រ **អាយ ខន** ថាមិនត្រឹមត្រូវព្រោះខុសនឹងមាត្រា៥១ ច្បាប់រដ្ឋធម្មនុញ្ញ ដែលចែងថា ***អំណាចបែងចែកដាច់ពីគ្នារវាង អំណាចនីតិបញ្ញត្តិ អំណាចប្រតិបត្តិ និងអំណាចតុលាការ*** ។

ហើយនៅពេលសភាពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាពអ្នកតំណាងរាស្ត្រ **សុន ឆ័យ** បានស្នើសុំថានាយករដ្ឋមន្ត្រីគួរធ្វើសេចក្តីព្រាងអនុក្រឹត្យចូលរដ្ឋសភាជាមុនសិន ហើយត្រូវអ្នកតំណាងរាស្ត្រ **អាយ ខន** ថាខុសពីនីតិវិធីដែរ។

ខុមហ្វ្រែល សង្កេតឃើញថាអ្នកតំណាងរាស្ត្រ **សុន ឆ័យ** បានធ្វើពាក្យសុំឡើងឆ្លើយតប តែសំណើនោះត្រូវបានបដិសេធដោយប្រធានរដ្ឋសភា។

ក្នុងបទសម្ភាសន៍ជាមួយ ខុមហ្វ្រែល អ្នកតំណាងរាស្ត្រ **សុន ឆ័យ** បានឱ្យដឹងថា មិនមានច្បាប់ណាដែលហាមអ្នកតំណាងរាស្ត្រឱ្យធ្វើសំណើដល់រាជរដ្ឋាភិបាលឡើយ ហើយការស្នើសុំឯកសារ និងអនុក្រឹត្យគឺដើម្បីឱ្យរដ្ឋសភាដឹងពីការងាររបស់រាជរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដោយរដ្ឋសភាប៉ុណ្ណោះ ហើយវាមិនមែនជាការលូកដៃចូលក្នុងការងាររបស់រាជរដ្ឋាភិបាលនោះទេ។

គួររំលឹកផងដែរថា ប្រធានរដ្ឋសភាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** កន្លងមកធ្លាប់បានលើកឡើងថា រដ្ឋសភាគឺជាស្ថាប័នកំពូលរបស់ជាតិ ហើយត្រូវតែអាចដឹងការងារទាំងអស់ លើកលែងតែការសម្ងាត់របស់ក្រុមហ៊ុនគេ។

## អ្នកតំណាងរាស្ត្រស្នើរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមកបំភ្លឺនៅសភា

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** មណ្ឌលភ្នំពេញ និងជាប្រធានគណៈកម្មការទី៤ រដ្ឋសភា បានស្នើសុំរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មកបំភ្លឺចំពោះសភាពេញអង្គ ពីករណីប្រើអំពើហឹង្សាបង្ក្រាបលើបាតុកម្ម កូដកម្ម និងក្បួនដង្ហែផ្សេងៗដោយសន្តិវិធី។

ក្នុងលិខិតដាក់ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** បានឱ្យដឹងថា **កងកម្លាំងប៉ូលីស បាននិងកំពុងប្រើប្រាស់អំពើហឹង្សាបង្ក្រាបទៅលើព្រះសង្ឃ ប្រជាពលរដ្ឋ និងសង្គមស៊ីវិល**ដែលបានចូលរួមក្នុង បាតុកម្ម កូដកម្ម និងក្បួនដង្ហែផ្សេងៗ។

ក្នុងលិខិតនោះក៏បានលើកឡើងផងដែរពីការបង្ក្រាបរបស់កងកម្លាំងប្រដាប់អាវុធដោយប្រើដំបងឆក់ និងវាយដំ ទៅលើព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយក្រុមដែលបាននិមន្តក្បួនដង្ហែដោយសន្តិវិធីដើម្បីនាំយកញត្តិសម្តែងមតិ ទាមទារឱ្យមានការគោរពសិទ្ធិមនុស្សនៅកម្ពុជា-ក្រោម ទៅជូនស្ថានទូតវៀតណាមនៅទីក្រុងភ្នំពេញ។

ទោះបីយ៉ាងណា ខុមហ្វ្រែលមិនទាន់បានទទួលព័តិស្តីពីការឆ្លើយតបពីរាជរដ្ឋាភិបាលនៅឡើយទេ។

## ការអនុម័តនានាដោយរដ្ឋសភា

នៅក្នុងសម័យប្រជុំទាំង ១៣ព្រឹក រដ្ឋសភាបានពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៨ ដែលក្នុងនោះមានសេចក្តីព្រាងច្បាប់ចំនួន ៥ សេចក្តីស្នើច្បាប់មួយ និងកិច្ចព្រមព្រៀងចំនួន ២ ដូចខាងក្រោម

- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីការដឹកជញ្ជូនពហុរូបភាព
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបសង្គ្រោះបន្ទាន់
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាព។

**************************************